# ហេតុអ្វីមានចម្លាក់រូបជនបរទេសនៅសំបូរព្រៃគុក?

កន្លងមក អ្នកស្រាវជ្រាវបានកត់សម្គាល់ និងហៅរូបចម្លាក់មួយចំនួននៅសំបូរព្រៃគុកថា មានមុខមាត់ជាជនបរទេស។ រូបចម្លាក់ដ៏ពិសេសទាំងនោះរួមមានដូចជា ចម្លាក់ទ្វារបាលមានមួកទ្រវែងស្លួចចុង និងទេពស្រីមានមួកត្រង់ស្រួចទៅលើនៅជញ្ជាំងប្រាសាទដើមចាន់ (N15) (រូបលេខ១) ចម្លាក់ទ្វារបាលមានមួករាងកោងទ្រវែងដូចគ្នាឆ្លាក់នៅជញ្ជាំងប្រាសាទយាយព័ន្ធ (S11) (រូបលេខ២) ចម្លាក់មរុតជិះសេះមានមួករាងទ្រវែងស្លួចចុងនៅលើផ្តែរទ្វារប្រាសាទយាយព័ន្ធ (S7) (រូបលេខ៣) និងចម្លាក់មុខមនុស្សឬទេពឆ្លាក់នៅក្នុងកូនបង្អួច (គូឌុ) ប្រាសាទអុក (S2) (រូបលេខ៤-៥) ជាដើម។ រូបជនបរទេសមួយចំនួនមានលក្ខណៈដូចទៅនឹងសិល្បៈនៅតំបន់អាស៊ីកណ្តាល (ប្រទេសពែរ្សបុរាណ ឬសាក) និងខ្លះទៀតស្រដៀងទៅនឹងអារ្យធម៌ហេលេនីស (Hellenistic) ទៀតផង (ឥទ្ធិពលសិល្បៈក្រិច-រ៉ូម៉ាំង)។ ចម្ងល់នោះ គឺនៅត្រង់ថា តើហេតុអ្វីបានជាសិល្បករនៅសម័យស.វ.ទី៧ ឆ្លាក់រូបចម្លាក់ទាំងនេះឡើង? តើឥទ្ធិពលនៃសិល្បៈបរទេសទាំងនេះចូលមកក្នុងសង្គមកម្ពុជានៅសម័យបុរាណតាមវិធីណា? តើកន្លងមកអ្នកស្រាវជ្រាវផ្តល់ជាសមិតិកម្ម ឬការសន្និដ្ឋានបែបណាខ្លះ?

នៅសម័យអាណានិគមបារាំង ក្នុងកំឡុងពេលដែលអ្នកស្រាវជ្រាវមកពីតំបន់អឺរ៉ុបមកសិក្សាអំពីបុរាណវិទ្យា និងប្រវត្តិសិល្បៈខ្មែរ គេពុំបានសិក្សាលម្អិតអំពីរឿងនេះឡើយ។ នៅឆ្នាំ២០០៩ អត្ថបទខ្លីមួយសរសេរដោយលោក ហេង ពិភាល់ ចុះផ្សាយក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ បានក្លាយជាទុនដ៏មានសារសំខាន់មួយសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយ។ លោកបានស្នើថា ចម្លាក់នៅជញ្ជាំងប្រាសាទដើមចាន់ (N15) និងប្រាសាទយាយព័ន្ធ (S11) ដែលមានចម្លាក់មនុស្សប្រុសពាក់មួករាងទ្រវែងស្លួចចុង និងមនុស្សស្រីមានចុងស្រួចឡើងលើ ស្រដៀងជាមួយមួករបស់ជនជាតិសាហ្សានៀន នៃប្រទេសពែរ្សបុរាណ ហើយដែលមានលក្ខណៈស្រដៀងគ្នាជាមួយរូបភាពនៅលើកាក់បុរាណដែលរកឃើញនៅតំបន់អូរកែវ កំពង់ផែនៅសម័យហ្វូណន។ សិល្បៈដែលចេញមកខាងក្រៅនេះ លោកយល់ថា ពុំមែនមកត្រង់ពីពែរ្សមកស្រុកខ្មែរនោះទេ ហើយអាចឆ្លងកាត់ឥណ្ឌាមួយដំណាក់កាលសិន។ លោកបានលើកតឹងតាងសិលាចារឹកនៅសំបូរព្រៃគុក K.438 រៀបរាប់អំពីបុត្រីស្តេចឦសានវរ្ម័នទី១ បានរៀបអភិសេកជាមួយព្រាហ្មណ៍មកពីឥណ្ឌាម្នាក់ (នគរទក្សិណបថ តំបន់ Deccan) ឈ្មោះថា "ទុគ៌ស្វាមិ" ដែលព្រាហ្មណ៍នេះគឺជាជនជាតិ "សាក" (Sāka) (អម្បូរជនជាតិមួយនៅក្នុងប្រទេសពែរ្សបុរាណ តំបន់អាស៊ីកណ្តាល) ហើយស្តេចប្រទានគោរម្យងារដល់ព្រាហ្មណ៍នេះជា "ម្រតាញ" (គោរម្យងារមន្ត្រីជាន់ខ្ពស់សម័យមុនអង្គរ)។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## អត្ថបទ៖ ហេតុអ្វីមានចម្លាក់រូបជនបរទេសសំបូរព្រៃគុក?

នៅក្នុងឆ្នាំ២០១៧ លោក តាំង រីនិត (Rinith Taing) ជាអ្នកសរសេរអត្ថបទព័ត៌មានប្រចាំកាសែតភ្នំពេញប៉ុស្តិ៍ បានចេញផ្សាយអត្ថបទមួយអំពីចម្លាក់ជនបរទេសនៅសំបូរព្រៃគុក។ នៅក្នុងអត្ថបទខ្លីនោះ លោកយោងទៅលើបទសម្ភាសន៍ជាមួយអ្នកស្រាវជ្រាវផ្នែកបុរាណវិទ្យា និងប្រវត្តិសិល្បៈខ្មែរចំនួន ២ រូប គឺលោក ចិន្ត ច័ន្ទរតនា និងលោក មីសែល ត្រាណេ។ ក្នុងនោះ លោក ចិន្ត ច័ន្ទរតនា យល់ថា ចម្លាក់រូបជនបរទេសឆ្លាក់នៅគូឱប្រាសាទអុក (រូបលេខ៤-៥) បង្ហាញអំពីមុខបុរសមកពីចក្រភពរ៉ូម ឬពែរក្ស ដែលបុរសទាំងនេះ អាចជាដៃគូពាណិជ្ជកម្មរបស់អាណាចក្រចេនឡា ចន្លោះឥណ្ឌា និងចិន។ លោកគិតដូច្នេះ ដោយសារយោងទៅលើការរកឃើញកាក់ជាច្រើននៅខេត្តអានយ៉ាង ប្រទេសវៀតណាម (អតីតកំពង់ផែអូរកែវ របស់ហ្វូណន) ដែលជាបុរាណវត្ថុតាំងពីរវាងស.វ.ទី១។ ព្រមជាមួយគ្នានេះ លោកសន្និដ្ឋានថា មនុស្សទាំងនេះអាចជាឈ្មួញដែលបានបរិច្ចាកប្រាក់កាក់និងធនធាន ដើម្បីសាងសង់ប្រាសាទជាមួយព្រះមហាក្សត្រខ្មែរ ទើបអាចមានរូបមុខពួកគេនៅលើប្រាសាទបាន។ ចំណែក លោក មីសែល ត្រាណេ លើកឡើងអំពីកំណត់ត្រាចិនដែលបានសរសេរថា មហេសីមួយអង្គរបស់ស្តេច គឺជាបុត្រីរបស់អ្នកគ្រប់គ្រងនៅឥណ្ឌាខាងត្បូង ម្ល៉ោះហើយស្តេចអាចនឹងកសាងប្រាសាទតម្រូវតាមព្រះទ័យរបស់មហេសី ហើយលោកជឿថា ចម្លាក់ទាំងនេះអាចមានឥទ្ធិពលជនជាតិពែរ្ស ព្រោះមុខមាត់ចម្លាក់នៅប្រាសាទអុកស្រដៀងជាមួយរូបភាពបុរសនៅលើកាក់ដែលរកឃើញនៅអូរកែវ។ លោកអះអាងថា "ពួកគេជាមនុស្សមកពីណា គឺនៅតែអាថ៌កំបាំង" ប៉ុន្តែ លោកស្មានថា "ពួកគេជាមនុស្សសំខាន់ដែលយ៉ាងហោចណាស់ក៏ជាមនុស្សជិតស្និទ្ធនឹងព្រះមហាក្សត្រ ឬមន្ត្រីជាន់ខ្ពស់ដែរ។

នៅក្នុងឆ្នាំ២០១៨ អត្ថបទដ៏លម្អិត និងមានសារសំខាន់មួយដែលជាស្នាដៃនិក្ខេបបទបញ្ចប់ថ្នាក់បណ្ឌិតរបស់លោក Ben Wreyford នៅសាកលវិទ្យាល័យ London ចក្រភពអង់គ្លេស។ ការសិក្សារបស់លោក មិនត្រឹមតែផ្តោតទៅលើរូបចម្លាក់ជនបរទេសដែលមាននៅសំបូរព្រៃគុកប៉ុណ្ណោះទេ គឺលោកបានពិនិត្យយ៉ាងល្អិតល្អន់អំពីចម្លាក់ជនបរទេស ដែលមាននៅអាស៊ីអាគ្នេយ៍ចន្លោះពីឆ្នាំ ១០០ ដល់ ៩០០ នៃគ្រឹស្តសករាជ ដោយលើកយកភស្តុតាងសំខាន់ៗធៀបជាមួយនឹងសិល្បៈដែលមាននៅតំបន់អឺរ៉ុប និងអាស៊ីកណ្តាល។ នៅតំបន់សំបូរព្រៃគុក លោកយល់ថា ចម្លាក់មរុតពាក់មួករាងទ្រវែងស្រួចចុង (ផ្តែរទ្វារ S7) ចម្លាក់នៅជញ្ជាំងប្រាសាទ S11 និង N15 គឺជាប្រភេទមួកម្យ៉ាងដែលគេហៅថា "ហ្វ្រីជៀន" (Phrygian cap)។ ហ្វ្រីជៀន គឺជាប្រភេទមួកទន់បត់ និងនិយមពាក់ដោយជនជាតិ "សាក" (Sāka) នៅតំបន់អាស៊ីកណ្តាល។ ចំណែក ស្បែកជើងរបស់មរុតពាក់នៅលើផ្តែរទ្វារ S7 ក៏ជាប្រភេទស្បែកជើងកវែងដែលឃើញមានប្រើប្រាស់នៅតំបន់អាស៊ីកណ្តាលដូច

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

គ្នាដែរ។ សំណួរសួរថា ហេតុអ្វីមានឥទ្ធិពលទាំងនេះចូលក្នុងសង្គមកម្ពុជា? លោកបកស្រាយថា ប្រទេសឥណ្ឌាដែលជាសម្ព័ន្ធមិត្តបុរាណរបស់កម្ពុជា តែងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រជាជននៅតំបន់អាស៊ីកណ្ដាល។ ជាពិសេស គឺទំនាក់ទំនងវប្បធម៌រវាងរាជវង្សគុសាន (Kuśāna) និងជនជាតិភាគតិចសាក (Sāka) ជាមួយក្រុមឥណ្ឌូ-អ៊ីរ៉ង់ ដែលតែងទាក់ទងក្នុងការបង្កាត់ពូជនិងធ្វើពាណិជ្ជកម្មជួញដូរសេះនៅភាគពាយព្យប្រទេសឥណ្ឌា។ ម្ល៉ោះហើយ ទើបការស្លៀកពាក់ និងប្រពៃណីជិះសេះមានលក្ខណៈស្រដៀងគ្នាច្រើន។ ក្នុងនោះ កំណត់ត្រាចិន រៀបរាប់ថា "នៅស.វ. ទី៧ គេបាននាំយកសេះជាច្រើនក្បាលចូលមកតំបន់អាស៊ីអាគ្នេយ៍ ជាពិសេស នៅតំបន់ទ្វារវតី (ប្រទេសថៃ) និងលីនយី (ចាម្ប៉ា)"។ ដូច្នេះ ពេលដែលនាំសេះយកមកប្រហែលជាមានការបង្ហាត់បង្ហាញពីអ្នកជំនាញជិះសេះពីបរទេសមកជាមួយដែរ។ ប៉ុន្តែ សម្រាប់ប្រទេសកម្ពុជា ពុំមានឯកសារណាមួយបញ្ជាក់ថាមានជួញដូរសេះជាមួយបរទេសឡើយ។ ទោះបីយ៉ាងណា ប្រសិនបើកម្ពុជាមានទំនាក់ទំនងក្នុងការជួញដូរសេះនេះដែរ នោះប្រហែលជាឥទ្ធិពលជនបរទេសដែលមាននៅចម្លាក់ខ្មែរ ក៏អាចកើតមានឡើងតាមរយៈវិធីនេះផងដែរ។ ម្យ៉ាងវិញទៀត ភស្តុតាងដ៏សំខាន់ទី២ គឺលោក Ben Wreyford យោងទៅលើសិលាចារឹកក្នុងស្រុកដូចលោក ហេង ពិភាល់ ធ្លាប់បានលើកឡើងខាងលើដែរ ដែលប្រហែលជាចម្លាក់ជនបរទេសកើតឡើងនៅសំបូរព្រៃគុក ដោយសារតែមានមន្ត្រីផ្នែកគ្រប់គ្រងសំណង់សាសនានៅសំបូរព្រៃគុក អាចជាជនជាតិណាមួយមកពីតំបន់អាស៊ីកណ្ដាល។ ក្នុងនោះ សិលាចារឹកទី១រកឃើញនៅប្រាសាទដើមចាន់ (N16) K.438 រៀបរាប់ថា "*បុត្រីរបស់ស្ដេចឦសានវរ្ម័នទី១ បានរៀបអភិសេកជាមួយព្រាហ្មណ៍មកពីឥណ្ឌាឈ្មោះ ទុគ៌ស្វាមិ ដោយព្រាហ្មណ៍នេះបានបង្ហាញអត្តសញ្ញាណរបស់ខ្លួនថា គាត់ គឺជាជនជាតិសាក*"។ វាពិតជាពិបាកជឿថា គាត់ជាជនជាតិសាក តែមានវណ្ណៈព្រាហ្មណ៍នោះ ប៉ុន្តែសិលាចារឹកមួយទៀតនៅក្រុមប្រាសាទយាយព័ន្ធ (N17-7) K.604 រៀបរាប់អំពីភូមិមួយឈ្មោះថា "*សាកតីថ៌*" ដែលជាភូមិចាត់ចែងជាអចិន្ត្រៃយ៍ដោយពពួកព្រាហ្មណ៍។ ដូច្នេះហើយ វាអាចជាសញ្ញាបញ្ជាក់ថា នៅស្រុកឥណ្ឌាប្រហែលជាមានភូមិមួយដែលមានជនជាតិសាក (Sāka) រស់នៅ ហើយតំបន់នោះប្រហែលជាអតីតទឹកដី "*ក្សត្រប*" (Kśatrapa) ភាគខាងលិចតំបន់គុជរត (Gujarata) និងតំបន់ Malwa។ ការសន្និដ្ឋានបែបនេះ គឺដោយសារតែលោកយោងទៅលើប្រភពឯកសារក្នុងស្រុកឥណ្ឌា ព្រមទាំងចម្លាក់មួយចំនួនដែលរកឃើញនៅរូបភ្នំ Aihole ដែលមានចម្លាក់ទ្វារបាលមួយមានសម្លៀកបំពាក់ស្រដៀងចម្លាក់ទ្វារបាលនៅប្រាសាទដើមចាន់ក្នុងតំបន់សំបូរព្រៃគុកដែរ (រូបលេខ៦)។ លោកក៏បានបញ្ជាក់បន្ថែមថា រជ្ជកាលរបស់ព្រះបាទឦសានវរ្ម័នទី១ ជាស្ដេចនៃអាណាចក្រចេនឡា គឺមាន

ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយឥណ្ឌានៅក្នុងសន្តតិវង្សចលុក្យ (Cālukya) តាមរយៈផ្លូវសមុទ្រ។ អាណាចក្រចេនឡារបស់កម្ពុជា និងអាណាចក្រចលុក្យរបស់ឥណ្ឌាខាងត្បូង គឺសុទ្ធសឹងស្ថិតនៅតំបន់ដីគោកដូចគ្នា។ ក្នុងនោះ សន្តតិវង្សចលុក្យ បានចាប់ផ្តើមឡើងនៅគ.ស.៥៦៦ (ស.វ.ទី៦) ហើយបានដួលរលំនៅគ.ស.៦៤២ ដែលត្រូវគ្នានឹងរជ្ជកាលរបស់ព្រះបាទឦសានវរ្ម័នទី១ ចាប់ពីគ.ស. ៦១៦ ដល់ ៦៣៧។ ដូច្នេះ ព្រាហ្មណ៍ទុគ៌ស្វាមិ ដែលប្រហែលជាជាប់ពូជពង្សជនជាតិសាក (Sāka) ទំនងជាបានមកកម្ពុជាតាមរយៈផ្លូវសមុទ្រនៅក្នុងរជ្ជកាលដែលគ្រប់គ្រងដោយសន្តតិវង្សចលុក្យ។

ជាសរុបរួមមក ការសន្និដ្ឋានរបស់លោក ហេង ពិភាល់ និងលោក Ben Wreyford គឺមានមូលដ្ឋានច្បាស់លាស់ និងចុះសម្រុងគ្នាប្រកបដោយគំនិតពិចារណាយ៉ាងជ្រាលជ្រៅ។ ចំណែកឯការសន្និដ្ឋានរបស់លោក ចិន្ទ ច័ន្ទរតនា និងលោក មីសែល ត្រាណេ គឺស្ថិតនៅក្នុងបរិបទស្រដៀងគ្នាដែរ ប៉ុន្តែមិនមានភស្តុតាងវិភាគបែបស៊ីជម្រៅនោះឡើយ។ ការសិក្សាចុងក្រោយរបស់លោក Ben Wreyford គឺជាឯកសារដ៏មានសារៈសំខាន់ក្នុងការស្វែងយល់អំពីប្រភពនៃចម្លាក់រូបជនបរទេសដែលលេចឡើងនៅតំបន់ប្រាសាទសំបូរព្រៃគុក។ ជាចុងក្រោយ យើងអាចសន្និដ្ឋានថាការដែលមានចម្លាក់រូបជនបរទេសកើតឡើង ប្រហែលជាមានវត្តមានជនបរទេសជាមន្ត្រីខាងទទួលបន្ទុកការកសាងប្រាសាទនៅសំបូរព្រៃគុកផ្ទាល់តែម្តង ហើយជនបរទេសនោះទៀតសោតគឺទំនងជាជនជាតិណាមួយនៃតំបន់អាស៊ីកណ្តាល តួយ៉ាងដូចជា ព្រាហ្មណ៍ ទុគ៌ស្វាមិ ដែលទំនងជាជនជាតិសាក មកពីស្រុកឥណ្ឌាផ្ទាល់។ សូមបញ្ជាក់បន្ថែមថា សិល្បៈនៅអាស៊ីកណ្តាល គឺភាគច្រើនតែងតែមានលាយឡំជាមួយឥទ្ធិពលសិល្បៈអារ្យធម៌ហេលេនិស (Hellenistic) ដែលកើតចេញពីសិល្បៈក្រិច និងរ៉ូម៉ាំង ម្ល៉ោះហើយទើបរូបចម្លាក់នៅប្រាសាទអុក (S2) មានសក់ និងពុកមាត់ ស្រដៀងទៅនឹងមនុស្សនៅសិល្បៈក្រិច និងរ៉ូម៉ាំងខ្លាំងបែបនេះ៕

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២១៖ វិមានអណ្ដែតនៅជញ្ជាំងប្រាសាទដើមចាន់ (N15) មានចម្លាក់រូបជនបរទេសពាក់មួយរាងទ្រវែងស្លួចចុង



រូបលេខ២១.១៖ លម្អិតចម្លាក់រូបជនបរទេសពាក់មួកទ្រវែងស្លួចចុងនៅប្រាសាទដើមចាន់ (N15)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៖ វិមានអណ្តែតនៅជញ្ជាំងប្រាសាទយាយព័ន្ធ (S11)
មានចម្លាក់រូបជនបរទេសពាក់មួយរាងទ្រវែងស្លួចចុង

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២.១៖ លម្អិតចម្លាក់រូបជនបរទេសពាក់មួកទ្រវែងស្លួចចុងនៅប្រាសាទយាយព័ន្ធ (S11)



រូបលេខ៣៖ ផ្តែរទ្វារប្រាសាទយាយព័ន្ធ (S7) មានចម្លាក់ព្រះមរុតជិះសេះពាក់មួករាងទ្រវែងស្លួចចុង និងមរុតម្នាក់ពាក់ស្បែកជើងកវែងក្នុងទម្រង់ជនបរទេសនៅអាស៊ីកណ្ដាល (សព្វថ្ងៃផ្តែរនេះរក្សាទុកនៅសារមន្ទីរជាតិហ្គីមេ ប្រទេសបារាំង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣.១៖ លម្អិតចម្លាក់មនុស្សពាក់មួកវាងទ្រវែងស្លួចចុងនិងស្បែកជើងកវែងជាជនបរទេស
នៅអាស៊ីកណ្តាលនៅលើផ្តែរទ្វារប្រាសាទយាយព័ន្ធ (S7)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣.២៖ លម្អិតចម្លាក់មនុស្សពាក់មួកវាងទ្រវែងស្លួចចុង ជាជនបរទេសនៅអាស៊ីកណ្ដាល នៅលើផ្តែរទ្វារប្រាសាទយាយព័ន្ធ (S7)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៨៖ ចម្លាក់រូបជនបរទេសឆ្លាក់នៅខាងក្នុងគូឱប្រាសាទអុក (S2) ក្នុងទម្រង់មុខស្រដៀង
សិល្បៈអារ្យធម៌ហេលេនិក (Hellenistic)



រូបលេខ២៩៖ ចម្លាក់រូបជនបរទេសឆ្លាក់នៅខាងក្នុងគូឱប្រាសាទអុក (S2) ក្នុងទម្រង់មុខស្រដៀង
សិល្បៈអារ្យធម៌ហេលេនិក (Hellenistic)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៦៖ ចម្លាក់រូបទ្វារបាលនៅរូងភ្នំ Aihole នៅឥណ្ឌាខាងត្បូង តំបន់គុជរត ដែលជាអតីតតំបន់មាននីគមជនជនជាតិសាករស់នៅ មានសម្លៀកបំពាក់ និងមួកស្រដៀងរូបទ្វារបាលប្រាសាទដើមចាន់នៅសំបូរព្រៃគុក ក្នុងរូបលេខ២១ (ប្រភព៖ Ben Wreyford)

## ឯកសារយោង


ហេង ពិភាល់ ២០០៩. ចម្លាក់រូបជនបរទេសនៅសម្បូណ៌ព្រៃគុក, *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ ៤ ភ្នំពេញ។

Ben, W. 2018. *Seeing the 'Foreigner' In The Art of Early Southeast Asia c. 1000 BCE – c. 900 CE,* Thesis submitted for the degree of PhD, SOAS University of London.

Rinith Taing, 2017. 'The mysterious 'foreigners' carved into the temples of Sambor Prei Kuk', *Phnom Penh Post*. 9 June 2017. Accessed 03 April 2023. https://www.phnompenhpost.com/post-depth-post-life-arts-culture/mysterious-foreigners-carved-temples-sambor-prei-kuk


អត្ថបទដោយ៖ ម៉ង់ វ៉ាលី